# ជំងឺរបេង : ហេតុការណ៍ពិត

## តើជំងឺរបេងគឺជាអ្វីទៅ ?
ជំងឺរបេង (ហៅថា TB ផងដែរ) គឺជាជំងឺមួយដែលបង្កដោយបាក់តេរី (មេរោគ)។ ជាធម្មតា ជំងឺរបេងកើតមាននៅនឹងសួត ប៉ុន្តែវាអាចឆ្លងរាលដាលទៅកាន់តម្រងនោម ឆ្អឹង ឆ្អឹងខ្នង ខួរក្បាល និង ផ្នែកឯទៀតរបស់រាងកាយ។

## តើ **TB** ឆ្លងតាមរបៀបណា ?
TB ឆ្លងតាមរយៈខ្យល់ នៅពេលក្អកឬកណ្តាស់ដោយអ្នកមានជំងឺរបេងសួតដែលមិនព្យាបាល។ ជាធម្មតា អ្នកដែលស្រូបយកមេរោគ TB តាមការដកដង្ហើម ត្រូវតែទាក់ទងប៉ះពាល់យ៉ាងជិតដិតជាខ្លាំងនៅរៀងរាល់ថ្ងៃ ជាមួយនឹងអ្នកណាមួយដែលកើតជំងឺនេះ។ ជំងឺនេះមិនឆ្លងតាមរយៈចាន ពែង សមស្លាបព្រា ក្រណាត់កំរាលពូក ឬ ខោអាវឡើយ។

## តើ **TB** ប៉ះពាល់យ៉ាងណាដែរដល់រាងកាយ ?
### ការមាន **TB**
អ្នកណាមួយដែលមានរបេង មានន័យថា អ្នកនោះមានមេរោគ TB នៅក្នុងខ្លួន។ ជាធម្មតា ប្រព័ន្ធការពាររោគរបស់អ្នកនោះ អាចប្រយុទ្ធនឹងមេរោគទាំងនេះបាន ដោយធ្វើឲ្យមេរោគទាំងនោះទៅជាអសកម្ម។ មេរោគទាំងនេះនឹងអសកម្មជានិច្ច នៅក្នុងចំណោមមនុស្ស 90% ។ អ្នកមានរបេង មិនធ្លាក់ខ្លួនឈឺទេ ហើយមិនអាចចម្លងជំងឺរបេងទៅកាន់អ្នកដទៃទៀតបានឡើយ។ គេហៅស្ថានភាពនេះថា ការមានរបេង**កំបាំង**។

### ជំងឺ **TB**
ជំងឺ TB គឺជាជំងឺមួយដែលបណ្តាលដោយមេរោគ TB **សកម្ម** ។ ជំងឺនេះអាចកើតមាននៅពេលដ៏ខ្លី ក្រោយពីមេរោគចូលទៅក្នុងរាងកាយ ឬ នៅពេលច្រើនឆ្នាំក្រោយមកទៀត នៅពេលដែលប្រព័ន្ធការពាររោគរបស់រាងកាយ មានភាពទន់ខ្សោយដោយសារតែកត្តាផ្សេងទៀត ដូចជាវ័យចំណាស់ ជំងឺទឹកនោមផ្អែម មានមេរោគ HIV ជំងឺតម្រងនោម ឬ មហារីក។ អ្នកដែលមានជំងឺ TB គឺមានមេរោគ TB សកម្ម **ព្រមទាំង**សញ្ញានៃការមានជំងឺ។

## តើ **TB** មានសញ្ញាអ្វីខ្លះទៅ ?
TB អាចវាយប្រហារទៅលើផ្នែកណាមួយនៃរាងកាយ ប៉ុន្តែសួតគឺជាកន្លែងទូទៅបំផុត។ អ្នកមានជំងឺ TB អាចមានសញ្ញាខ្លះ ឬ ទាំងអស់ ក្នុងចំណោមសញ្ញាដូចតទៅនេះ :
- មានអារម្មណ៍អស់កម្លាំងជានិច្ច
- បាត់បង់ចំណង់បរិភោគចំណីអាហារ
- ស្រកទម្ងន់ដោយគ្មានមូលហេតុ
- ក្អកយូរជាងបីអាទិត្យ
- គ្រុនក្តៅ
- បែកញើសនៅពេលយប់

ជួនកាលទៅ អ្នកមាន TB អាចក្អកចេញកំហាកដែលមានស្នាមឈាម។ អ្នកខ្លះដែលមានជំងឺ TB សកម្ម អាចមានតែរោគសញ្ញាមិនសូវធ្ងន់ធ្ងរប៉ុណ្ណោះ។

## តើតេស្តធម្មតាសំរាប់ TB មានអ្វីខ្លះទៅ ?

1. **តេស្តជោះស្បែករកមើលរបេង** (តេស្ត Mantoux) បង្ហាញថា តើអ្នកណាមួយទំនងជាមានរបេងដែរឬទេ
2. **ថតទ្រូងដោយកាំរស្មីអ៊ិក្ស** អាចបង្ហាញថា តើ TB មានកើតនៅនឹងសួតឬទេ
3. **តេស្តកំហាក** បង្ហាញថា តើមេរោគ TB មានវត្តមាននៅក្នុងកំហាកដែលចេញតាមរយៈកម្អកដែរឬទេ

## តើអ្នកណាដែលគួរធ្វើតេស្ត TB?

- អ្នកដែលមានសញ្ញាណាមួយនៃជំងឺ TB ។
- អ្នកដែលរស់នៅនិងធ្វើការដោយមានការទាក់ទងប៉ះពាល់ជិតដិតជាមួយអ្នកណាមួយដែលគេដឹងឬសង្ស័យថា មានជំងឺ TB នៅនឹងសួត។
- អ្នកដែលមានមេរោគ HIV ឬស្ថានភាពជំងឺមួយទៀតដែលធ្វើឲ្យអ្នកទាំងនេះមានលទ្ធភាពគ្រោះថ្នាក់ខ្លាំងក្នុងការកើតជំងឺ TB ។

## តើគេព្យាបាល TB តាមវិធីណា ?

**ការមាន TB:** វេជ្ជបណ្ឌិតអាចចេញបញ្ជាឲ្យប្រើថ្នាំគ្រាប់តាមចំនួនកំណត់មួយ ឬ ឲ្យថតមើលទ្រូងតាមរយៈកាំរស្មីអ៊ិក្ស ជាប្រក្រតី។
**ជំងឺ TB:** ត្រូវលេខថ្នាំគួបផ្សំនៃថ្នាំអង់ទីប៊ីយោទិកពិសេស រយៈពេលយ៉ាងតិច 6 ខែ។ វាជាការសំខាន់ណាស់ក្នុងការចងចាំថា គេអាចព្យាបាល TB ដោយងាយស្រួល បើលេបថ្នាំព្យាបាលឲ្យបានត្រឹមត្រូវ និង ឲ្យបានចប់សព្វគ្រប់។ យ៉ាងណាមិញ TB អាចវិលមកវិញ ហើយរឹតតែលំបាកព្យាបាល បើមិនលេបថ្នាំឲ្យបានទៀងទាត់ តាមចំនួនកំណត់ពេញលេញសំរាប់ការព្យាបាលទេនោះ។

## តើអ្នកជំងឺ TB អាចចម្លងរោគនេះជានិច្ចឬ ?

អ្នកមានជំងឺ TB នៅនឹងសួត ឬ បំពង់ក អាចចម្លងទៅអ្នកដទៃបាន។ អ្នកមាន TB នៅក្នុងផ្នែកឯទៀតនៃរាងកាយ ពុំអាចចម្លងរោគនេះបានទេ។ នៅក្នុងករណីភាគច្រើន ក្រោយពេលប្រើថ្នាំ TB ពីរអាទិត្យមក អ្នកដែលមានជំងឺ TB នឹងមិនចម្លងមេរោគនេះតទៅទៀតឡើយ។ បើអ្នកជំងឺអាចចម្លងរោគបាន គិលានុបដ្ឋាយិកាម្នាក់មកពីកម្មវិធីរបេង នឹងពិនិត្យវាយតម្លៃអ្នកណាទៅដែលត្រូវធ្វើតេស្ត ហើយរៀបចំឲ្យធ្វើតេស្តនេះ។ ជាញឹកញយ "អ្នកទាក់ទងប៉ះពាល់" គឺជាសមាជិកគ្រួសារ ប៉ុន្តែអាចជាមិត្តភក្តិជិតស្និទ្ធ ឬ អ្នកធ្វើការជាមួយ។ ការតាមរកមើលអ្នកទាក់ទងប៉ះពាល់ត្រូវបានធ្វើទៅដោយមានការប្រយ័ត្នប្រយែង និង លាក់ការសម្ងាត់ជានិច្ច។

## តើខ្ញុំអាចចាក់ថ្នាំបង្ការ TB បានឬទេ ?

គេមិនស្នើឲ្យសហគមន៍អូស្ត្រាលីទូទៅចាក់ថ្នាំបង្ការ BCG (ថ្នាំបង្ការ TB) ទេ នៅពេលដែលលទ្ធភាពគ្រោះថ្នាក់កើតមាន TB មានកំរិតទាបនោះ។ ថ្នាំបង្ការ BCG គឺសំរាប់ក្រុមជាក់លាក់ទាំងឡាយដែលមានលទ្ធភាពគ្រោះថ្នាក់ខ្លាំងនៃការកើតមាន TB តែប៉ុណ្ណោះ។

## ដើម្បីទទួលពត៌មានបន្ថែម សូមទាក់ទង

Mycobacterial Infections Program (កម្មវិធីជំងឺមេរោគឆ្លង)
Communicable Diseases Section (ផ្នែកជំងឺឆ្លង)
Department of Human Services (ក្រសួងផ្តល់កិច្ចបំរើពលរដ្ឋ)
GPO Box 1670N
Melbourne 3001
ទូរស័ព្ទ : 1300 651 160

លោកអ្នកអាចទទួលជំនួយបកប្រែភាសាតាមរយៈកិច្ចបំរើបកប្រែភាសា (TIS) ដោយបង់ថ្លៃទូរស័ព្ទក្នុងស្រុក តាមលេខ 13 14 50

## ប័ណ្ណពត៌មាន មានជាភាសា :

| | | |
|---|---|---|
| អារ៉ាប់ | ខ្មែរ | ចិន |
| ក្រូអាទី | ដារី | សូម៉ាលី |
| វៀតណាម | | |

ពត៌មាននេះ មាននៅតាមអ៊ីនធើរណិត :
http://www.health.vic.gov.au/ideas